# ករណីសិក្សា
# បញ្ហារោគលើស្បែករបស់កសិករ ពាក់ព័ន្ធនៅនឹងការដាំត្រកួន
# នៅក្នុងបឹងជើងឯក ក្រុងភ្នំពេញ ប្រទេសកម្ពុជា

ដោយ: លោក សុខ សីហា[១] និង លោក វួន ធួនអាន់[២]

១- សាកលវិទ្យាល័យភូមិន្ទកសិកម្ម ក្រុងភ្នំពេញ ប្រទេសកម្ពុជា

២- វិទ្យាស្ថានជាតិ អនាម័យ និង ជំងឺឆ្លង ក្រុងហាណូយ ប្រទេសវៀតណាម

បឹងជើងឯកគឺជា បឹងស្តុកទឹកធំមួយ ដែលមានទំហំ ៣៤00 ហិចតា ស្ថិតនៅចំងាយ ៥ គម ខាងត្បូងក្រុងភ្នំពេញ។ បឹងនេះទទួលទឹកសំណល់បរិមាណ៨0ភាគរយ នៃបរិមាណទឹកសំណល់ដែលបង្ហូរចេញពីក្រុងភ្នំពេញ ហើយប្រជាជនដែលរស់នៅជុំវិញបឹងនេះភាគច្រើនជាអ្នកដាំដំណាំបន្លែជលផល ឬ បន្លែទឹក មួយចំនួន ជាពិសេស បន្លែត្រកួន (*Ipomooea aquatica*) និង បន្លែកញ្ឆែត (*Neptunia oleracea*)។ បឹងនេះមានសារៈសំខាន់ណាស់សំរាប់ជីវភាពរស់នៅរបស់សហគមន៍នៅក្នុងតំបន់ តាមរយៈសកម្មភាពមួយចំនួនដូចជា ការដាំបន្លែជលផល និងការធ្វើនេសាទ។ ទោះបីជាយ៉ាងនេះក្តី ការងារប្រចាំថ្ងៃរបស់គាត់ ត្រូវធ្វើការប៉ះផ្ទាល់ជាមួយទឹកកាកសំណល់ជាពិសេសអ្នកដាំបន្លែជលផល ដែលជានិច្ចកាលតែងទទួលរងការប៉ះពាល់ដល់ផ្នែកសុខភាព ជាឧទាហរណ៍ បញ្ហាស្បែកដែលបណ្តាលមកពីទឹកសំណល់ ដែលជាញឹកញាប់កើតនៅចុងរដូវប្រាំងនិងនៅដើមរដូវភ្លៀង (មេសា-មិថុនា) (របាយការណ៍ ស្ថានភាពប្រព័ន្ធ របស់គំរោង PAPUSSA ឆ្នាំ ២00២)។ ដោយយោងតាម ទិន្នន័យដែលប្រមូលបានពីគ្រួសារដែលធ្វើសំភាសន៍ក្នុងបញ្ជីសំនួរមូលដ្ឋាន និងបញ្ជីសំនួរតាមដានរបស់គំរោង បានបង្ហាញអោយឃើញថាស្ទើរតែអ្នកដាំបន្លែជលផលទាំងអស់ ដែលរស់នៅជុំវិញបឹងជើងឯក តែងតែកើតមានបញ្ហាស្បែកជារៀងរាល់ឆ្នាំ។ ហេតុដូច្នេះហើយ ការសិក្សាពិសេស ចំនួន ៣ លើក លើបញ្ហាស្បែករបស់ប្រជាជន ដែលធ្វើការជាមួយទឹកកាកសំណល់នៅក្នុងបឹង ដោយអនុវត្តឡើង ពីខែ កក្កដា ២00៤ ដល់ខែ ឧសភា ឆ្នាំ២00៥ ដោយវិទ្យាស្ថានជាតិ អនាម័យ និងជំងឺឆ្លង ក្រុងហាណូយ ប្រទេសវៀតណាម សហការជាមួយ សាកលវិទ្យាល័យ ភូមិន្ទកសិកម្ម ក្រុងភ្នំពេញ និងអ្នកជំនាញខាងសុខភាពមកពី ប្រទេសដាណឺម៉ាក់។ ក្នុងការធ្វើការសិក្សាលើបញ្ហាស្បែកនោះ លទ្ធបានបានបង្ហាញថា ប្រជាជនដែលបានធ្វើសំភាសន៍នៅក្នុងការធ្វើអង្កេតមូលដ្ឋានមាន ៣២ ភាគរយ ,ការអង្កេតតាមដានលើកទី ១ (៥-៣១ កក្កដា ២00៤)មាន ៤២ភាគរយ , ការធ្វើអង្កេតតាមដានលើកទី ២ (៨ វិច្ឆិកា-៨ ធ្នូ ២00៤)មាន ៤៤ ភាគរយ និងការធ្វើអង្កេតតាមដានលើកទី ៣ (១ មករា-៤កុម្ភៈ ២00៥ មាន ៦0 ភាគរយ មានបញ្ហាស្បែកដែលកើតតាំងពីមួយខែមុនការធ្វើអង្កេត។ កសិករដែលបានធ្វើសំភាសន៍ឃើញមានបញ្ហាស្បែក នៅក្នុងកំឡុងពេលធ្វើ

ការសិក្សានោះ ត្រូវបានបញ្ជូនទៅកាន់ គ្លីនិកជាតិ ជំងឺសើរស្បែក និង កាមរោគ នៅក្នុងក្រុងភ្នំពេញ សំរាប់ពិនិត្យ និង ព្យាបាល។ ទិន្នន័យពីការសិក្សាបញ្ហាស្បែក ខាងលើត្រូវបាន ធ្វើការវិភាគ នៅវិទ្យាស្ថាន ជាតិ អនាម័យ និងជំងឺឆ្លង ក្រុងហាណូយ ប្រទេសវៀតណាម និង បោះពុម្ពចេញផ្សាយនៅពេល ក្រោយ។

ជាទូទៅ នៅពេលធ្វើសំភាសន៍ មានកសិករក្នុងតំបន់មួយចំនួនបាននិយាយថា ជាធម្មតាពួកគាត់ព្យាបាលជំងឺសើរស្បែក ដោយខ្លួនឯងផ្ទាល់ ដោយប្រើទូវវិធីសាស្ត្របុរាណ ដូចជា ក្រូចឆ្មា សាច់ដូរ និង ម្សៅជូរ។ ពួតគាត់យកមក លាយចូលគ្នា ហើយយកទៅលាបនៅដៃ ជើង និងកន្លែងផ្សេងៗនៅលើដងខ្លួនដែលកើតមានជំងឺដោយសារការប៉ះពាល់ ជាមួយទឹកកាកសំណល់។ ដោយយោងទៅតាមការធ្វើវិនិច្ឆ័យរោគលើអ្នកជំងឺដែលមានបញ្ហាស្បែកទាំងនោះ រោគ



សញ្ញាសំខាន់ៗ ដែលរកឃើញនៅលើស្បែកមាន ដូចជា : រមាស់ ពងតូចៗ និង ស្បែកស្ងួត ដែលជាធម្មតាកើតនៅលើ អ្នកដាំត្រកួននៅជុំវិញបឹងជើងឯក។ ដៃ គឺជា ផ្នែកមួយនៃរាងកាយដែលជានិច្ចកាល ប៉ះពាល់ជាងគេ ដោយការធ្វើការផ្ទាល់ ជាមួយទឹកកាកសំណល់រយៈពេលពេញមួយថ្ងៃ។ ជាងនេះទៅទៀតផ្នែកផ្សេងៗនៃរាងកាយ ដូចជា ជើង ប្រអប់ជើង និង តួខ្លួនទាំងមូល ក៏ទទួលរងដែរ។

លោក អ៊ុក មករា អាយុ ២៥ ឆ្នាំ ជាអ្នកដាំត្រកួន នៅក្នុងភូមិក្បាលទំនប់ ដែលមានទីលំនៅនៅក្បែរបឹងជើងឯក។ គាត់រៀបការនៅក្នុងឆ្នាំ ២០០០ ហើយមានកូនប្រុស ចំនួន ៣ នាក់ ដែលកូនច្បង មានអាយុ ៥ ឆ្នាំ កូនប្អូន មានអាយុ ៣ ឆ្នាំ និង កូនពៅ មានអាយុ ១ ឆ្នាំ ។ តាំងពីឆ្នាំ ១៩៩៧ គាត់បានទទួលដីសំរាប់ធ្វើត្រកួន ពីឪពុកម្តាយរបស់គាត់ ដែលមានទំហំដី ២ ហិចតា នៅក្នុងបឹងជើងឯក នៅក្បែរផ្ទះរបស់គាត់។ មុខរបរសំខាន់របស់គាត់គឺដាំត្រកួន និង មុខរបរបន្ទាប់បន្សំគឺ ការធ្វើនេសាទ ដើម្បីចិញ្ចឹមមនុស្សចំនួន ៧ នាក់ នៅក្នុងគ្រួសារ រួមមាន គាត់ ប្រពន្ធរបស់គាត់ ម្តាយ ប្អូនថ្លៃម្នាក់ និង កូនចំនួន ៣ នាក់។ សមាជិកនៅក្នុងគ្រួសារទាំងអស់លើកលែង តែកូនតូចៗទាំង ៣ បានចូលរួមក្នុងសកម្មភាពដាំដុះត្រកួន ដូចជា ការរៀបចំស្រែ ការរៀបចំពូជ ការថែទាំ ការដាក់ជី និង ការបាញ់ថ្នាំ ព្រមទាំងការប្រមូលផលផងដែរ។ លោក មករា គឺជាអ្នកទទួលខុសត្រូវធ្ងន់ជាងគេ ដូចជា ការបោះបង្គោលចងខ្សែសំរាប់ធ្វើរងត្រកួន និង ការបាញ់ថ្នាំគីមី ចំណែកឯប្រពន្ធរបស់គាត់ និង ម្តាយក្មេករបស់គាត់ គ្រាន់តែជាអ្នកថែទាំ និង ប្រមូលផលត្រកួនប៉ុណ្ណោះ ព្រោះពួកគេមិនអាចធន់ទ្រាំនឹងការងារធ្ងន់ និងការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិត (ដោយសារពួកគេមានសុខភាពខ្សោយ)។ ទោះបីជាប្អូនថ្លៃ របស់ លោក មករា រស់នៅក្រោមដំបូលផ្ទះជាមួយក៏ដោយ

ក៏គាត់មានចំណែកដីសំរាប់ដាំ ត្រកួនដើម្បីរកប្រាក់ចំណូល និង សន្សំលុយ ដើម្បីបង្កើតគ្រួសារតូចមួយដោយខ្លែក។ សមាជិកនៅក្នុងគ្រួសាររបស់លោក មករា អាចប្រមូលផលត្រកួនបាន ៣០០ ទៅ ៤០០ បាច់ ក្នុងមួយថ្ងៃ (១បាច់=0.៥ គក)។ ទោះបីជាយ៉ាងណាក៏ដោយ កសិករប្រមូលផលត្រកួនទៅតាមបរិមាណ ប្រមូលទិញរបស់ឈ្មួញ ដែលមកទិញពីកសិករ។ គាត់អាចលក់ បានក្នុងតំលៃ ពី ២០០ ទៅ ៣០០ រៀល ក្នុង មួយបាច់ (0.0៥ — 0.0៧៥ ដុល្លា) ទៅឈ្មួញ។ លោក មករា ចំណាយពេល ៣ ទៅ ៤ ម៉ោង ក្នុងមួយថ្ងៃ (៣ ទៅ ៤ ថ្ងៃ ក្នុង មួយសប្តាហ៍) សំរាប់ការបាញ់ថ្នាំសំលាប់សត្វល្អិត។ នៅក្នុងការបាញ់ថ្នាំ គាត់ប្រើប្រាស់តែ ម៉ាស់មុខប៉ុណ្ណោះ សំរាប់ការពារមុខរបស់គាត់។ គាត់ចំណាយពេល ពី ៦ ទៅ ៧ ម៉ោងក្នុងមួយថ្ងៃ ក្នុងការប្រមូលផល ប៉ុន្តែគាត់មិនអាចជួយសមាជិកនៅក្នុង គ្រួសាររបស់គាត់បានទេ ព្រោះគាត់ប្រមូលផល យឺតជាងប្រពន្ធរបស់គាត់ ។ លោក មករា បាន និយាយថា គាត់ទទួលរងបញ្ហាសុខភាពដែរ ដូចជា ផ្តាសសាយ អស់កំលាំង រមាស់ វិលមុខ។ល។ កំឡុងពេលបាញ់ថ្នាំ។ បញ្ហាសុខភាពធ្វើអោយរំខានដល់ការប្រកបការងារ របស់គាត់ ដូចជា ពងលើ ស្បែក



*គ្រួសាររបស់ មករា កំពុងប្រមូលផលត្រកួន*

រមាស់ស្បែក ក្រម និងរមាស់ ដែលបណ្តាល អោយគាត់ឈប់ធ្វើការ ហើយអាចស្នាក់នៅផ្ទះនៅ ក្នុងករណីជំងឺប្រែទៅជាធ្ងន់។ ម្រាមដៃ និង ម្រាមជើង ទទួលរងធ្ងន់ជាងគេ ទោះបីជាពួកគេប្រើស្រោម កំណាត់សំរាប់ការពារកំឡុងពេលធ្វើការ និង ប្រមូលផលក៏ដោយ លោក មករា បាននិយាយថា សមាជិកគ្រួសារ របស់គាត់ផ្សេងៗទៀត ក៏ទទួលរងនូវបញ្ហាស្បែក ផងដែរ ដូចជា មានខ្ទុះពងទឹក ឡើងជាប្រទាលត្រអាក រមាស់ ទឹកស៊ីក្រចកដៃ ក្រចកជើង ពងលើស្បែក និង មានក្រម ។ល។ ជាទូទៅ មានបញ្ហា ២ សំខាន់ៗ បណ្តាលអោយមាន បញ្ហាស្បែក និង បញ្ហាសុខភាព ដែលកើតមាន នៅលើប្រជាជនដែលរស់នៅជុំវិញបឹង គឺទី ១ ការបាញ់ថ្នាំសំលាប់ សត្វល្អិត និង ទី២ គឺ ការប្រមូលផលត្រកួន នៅក្នុង ទឹកកាកសំណល់។ នៅក្នុងរដូវប្រាំង (មេសា-មិថុនា) ស្ទើរតែ កសិករទាំងអស់ដែល នៅជុំវិញបឹង ទទួលរងនូវការ រមាស់ ដោយសារពួកគេចុះផ្ទាល់ទៅក្នុងទឹកតែម្តង (ដៃ និង ជើង) នៅនៅពេលទឹករាក់



*ពងខ្ទុះ និង រមាស់កើតលើស្បែករបស់សមាជិកគ្រួសារ*

ព្រោះនៅរដូវនេះ គេមិនអាចប្រើប្រាស់ទូកបានទេ។ ជាងនេះ ទៅទៀត នៅក្នុងរដូវប្រាំងពុំមានទឹកភ្លៀងហូរចូល និង ទឹកកាកសំណល់ ដែលបង្ហូរចេញពីទីក្រុង ផ្ទុកទៅដោយសារធាតុមានជាតិពុលខ្ពស់ រួមមានសារធាតុលោហៈធ្ងន់ៗ។

ដូចទៅនឹងគ្រួសារផ្សេងៗទៀតដែល ពាក់ព័ន្ធទៅនឹងការដាំត្រកួន លោក មករា ជានិច្ចកាល គាត់ព្យាបាល ដោយខ្លួនគាត់ផ្ទាល់ ដោយប្រើប្រាស់ ទឹកក្រូចឆ្មា និង ម្សៅជូរ សំរាប់បញ្ហាស្បែករបស់គាត់។ ប្រសិនបើគាត់នៅឆ្ងាយពី ការប៉ះពាល់ទឹកកាកសំណល់ បញ្ហាស្បែករបស់គាត់អាចនឹងបាត់ទៅវិញ ក្នុងរយៈពេល មួយសប្តាហ៍ក្រោយមក។ ប្រសិនបើវាមិនបាត់ទេ ជាធម្មតាគាត់នឹងទៅជួបគ្រូពេទ្យនៅក្នុងភូមិ រឺ គ្លីនិកជាតិជំងឺសើរស្បែក និងកាមរោគ នៅក្នុងក្រុងភ្នំពេញ។

នៅពេលដែលសួរសំនួរអំពី ពីអនាគត ពី ផលប៉ះពាល់ប្រព័ន្ធផលិតកម្មត្រកួន ទឹកសំណល់ លើសុខភាព លោក មករា ជឿថា បញ្ហាស្បែករបស់គាត់ និង ប្រជាជននៅក្នុងតំបន់ អាចនឹង ក្លាយទៅជាករណីដ៏ធ្ងន់ធ្ងរ ប្រសិនបើមិនមាន វិធានការណ៍ក្នុងការសំអាតទឹកកាកសំណល់ ដែលចេះតែកើនឡើងពីការបង្ហូរចេញពីទីក្រុងទេនោះ ជាពិសេស ទឹកសំណល់ពីរោងចក្រ ដែលនៅជុំវិញបឹង ។ នៅចុងបញ្ចប់ គាត់បានបន្ថែមទៀតថា ការបំពុលដែលចេះតែកើនឡើង នៅក្នុងទឹកកាកសំណល់ដែលមិនមានប្រព្រិត្តកម្មសំអាតនោះ មិនត្រឹមតែប៉ះពាល់សុខភាពរបស់ប្រជាជននៅក្នុង តំបន់ បឹងនោះប៉ុណ្ណោះទេ វាថែមទាំងប៉ះពាល់ដល់ការដាំដុះ និងផលិតកម្មបន្លែជលផលនៅក្នុងបឹង ដែលជាប្រភព ចំណូលដ៏សំខាន់មួយសំរាប់ប្រជាជន ដែលរស់នៅជុំវិញបឹងជើងឯក។